**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១៤១ អនក្រ.បក**

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៤៨៨ ហិកតា**

**ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកជ័យសែន ខេត្តព្រះវិហារ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ស ម្រេ ច**

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៦.៤៨៨ ( ប្រាំមួយពាន់បួនរយប៉ែតសិបប្រាំបី) ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំតស៊ូ ឃុំស្អាង និងឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ អាកាស្យា និងអំពៅ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៣១៥ចណលផ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១១ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រប តាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

## ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហេង ឈុង(ខេមបូឌា) អ៊ិនវេស្ទមិនគ្រុប ខមភេនី ស្ថិតនៅភូមិ ឃុំតស៊ូ ឃុំស្លាង និងឃុំកុឡែន ស្រុកជ័យសែន ខេត្តព្រះវិហារ




សញ្ញាសំគាល់ :
- ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ច
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ផ្លូវទឹក
- ផ្លូវ
- សាភតរទីព្រៃឈើ
- ព្រៃត្រូវរក្សាទុកបន្ថែមទៀត
- ដីសម្បទានសង្គមកិច្ច
- ព្រៃការពារប្រភពទឹក

គំរបព្រៃឆ្នាំ២០០៦ :

| | |
|---|---|
| ព្រៃពាក់កណ្ដាលស្រោង | ៩៨១ ហ.ត |
| ព្រៃល្បោះ | ១១ ៥៦៧ ហ.ត |
| ព្រៃផ្សេងៗ | ៨ ហ.ត |
| ដីគ្មានព្រៃ | ១៦៤ ហ.ត |
| សរុប : | ១២ ៣២០ ហ.ត |

និយាមការ ចំណុចក្បាលគោល :

| Coor_x | Coor_y | N |
|---|---|---|
| 520000. | 1504248. | a |
| 516609. | 1504247. | b |
| 526570. | 1504703. | e |
| 520000. | 1507222. | d |
| 516423. | 1507166. | c |
| 523149. | 1499248. | h |
| 523360. | 1499778. | g |
| 523901. | 1499788. | f |

| Coor_x | Coor_y | N |
|---|---|---|
| 514821. | 1506644. | 1 |
| 514745. | 1507070. | 2 |
| 514334. | 1507575. | 3 |
| 518064. | 1510235. | 4 |
| 513730. | 1511574. | 5 |
| 518598. | 1510024. | 6 |
| 514412. | 1511742. | 7 |
| 518102. | 1509141. | 8 |
| 518721. | 1509322. | 9 |
| 514200. | 1512293. | 10 |
| 513661. | 1512081. | 11 |
| 514290. | 1511374. | 12 |

លេខ ...០៧/០១១
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ធ្វើនៅ ថ្ងៃទី ...០៤... ឆ្នាំ២០១១
មេឃុំ
ចាន់_ស្រ៊ី

លេខ 220
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ស្លាង ថ្ងៃទី 22 ខែ 04 ឆ្នាំ២០១១
មេឃុំ
កេស_សិត

លេខ 154
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
កុឡែន ថ្ងៃទី 22 ខែ 04 ឆ្នាំ២០១១
មេឃុំ
ដួង_ចន្ធ្រូះ

លេខ ...
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ជ័យសែន ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
អភិបាលស្រុក
ថោង_សាគឿន

លេខ 312 ...
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី 22 ខែ 4 ឆ្នាំ២០១១
អភិបាលខេត្ត
អ៊ុំ មារ៉ា

លេខ 119 ...
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី ... ខែ 04 ឆ្នាំ២០១១
ប្រធានមន្ទីរកសិកម្ម
គឹម_ធ្វើដា

លេខ 109 ...
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី 22 ខែ 04 ឆ្នាំ២០១១
ប្រធានមន្ទីរបរិស្ថាន
...
គង់_សោភ័ណ